**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើត ការគ្រប់គ្រង និងការចាត់ចែងមូលនិធិអភិវឌ្ឍព្រៃឈើជាតិនិង ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋានការដំឡើងរដ្ឋបាលព្រៃឈើរដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋានការដំឡើងនាយកដ្ឋានកៅស៊ូក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

www.pheakdeylaw.com

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងបង្កើត **មូលនិធិអភិវឌ្ឍព្រៃឈើជាតិ** ដែលសរសេរជាអក្សរកាត់ថា "ម.អ.ព.ជ." និង**គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិ** ដែលសរសេរជាអក្សរកាត់ថា "គ.អ.ព.ជ."។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅប្រមូល គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់មូលនិធិអភិវឌ្ឍព្រៃឈើជាតិឱ្យមានប្រសិទ្ធភាពដើម្បីជួយទ្រទ្រង់និងអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិ ដើម្បីទ្រទ្រង់ អភិរក្ស និងអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ប្រភពចំណូលនិងការប្រើប្រាស់មូលនិធិអភិវឌ្ឍព្រៃឈើជាតិ

**មាត្រា៤.-**

មូលនិធិអភិវឌ្ឍព្រៃឈើជាតិមានប្រភពចំណូលមកពី៖

១- វិភាគទានផ្សេងៗរបស់រាជរដ្ឋាភិបាល។
២- បុព្វលាភលើផល អនុផលព្រៃឈើ។
៣- ប្រាក់ចំណូលអភិរក្សសត្វព្រៃ។
៤- ជំនួយរបស់អង្គការអន្តរជាតិនានា។
៥- អំណោយពីសប្បុរសជននិងអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តរជាតិ។
៦- កម្រៃសេវាផ្សេងៗពីវិស័យព្រៃឈើ។
៧- ប្រភពផ្សេងៗទៀត។

រាល់ចំណូលខាងលើត្រូវបញ្ចូលក្នុងគណនីមូលនិធិអភិវឌ្ឍព្រៃឈើជាតិ។

**មាត្រា៥.-**

មូលនិធិអភិវឌ្ឍព្រៃឈើជាតិត្រូវបានប្រើប្រាស់ក្នុងសកម្មភាពដូចខាងក្រោម៖

១- ការដាំដើមឈើឡើងវិញ។
២- កិច្ចការរុក្ខវប្បកម្មនិងការស្តារព្រៃឈើឡើងវិញ។
៣- កិច្ចការពារនិងអភិរក្សព្រៃឈើនិងជីវៈចម្រុះ។
៤- ការស្រាវជ្រាវបច្ចេកទេសនិងវិទ្យាសាស្ត្រនៃព្រៃឈើនិងសត្វព្រៃ។
៥- ការផ្សព្វផ្សាយអំពីវិស័យព្រៃឈើនិងសត្វព្រៃ។
៦- ការអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃ។



www.pheakdeylaw.com

៧- ការអភិវឌ្ឍសហគមន៍ព្រៃឈើ។

៨- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យព្រៃឈើនិងសត្វព្រៃ។

**មាត្រា៦ ..**

នីតិវិធីនៃការប្រើប្រាស់មូលនិធិអភិវឌ្ឍព្រៃឈើជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិ

**មាត្រា៧ ..**

មូលនិធិអភិវឌ្ឍព្រៃឈើជាតិស្ថិតនៅក្រោមការគ្រប់គ្រងចាត់ចែងនិងទទួលខុសត្រូវដោយគណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិដែលមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសហប្រធាន។

សមាសភាពគណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិ រួមមាន៖

- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហប្រធាន
- ប្រធានរដ្ឋបាលព្រៃឈើ អនុប្រធាន
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ១រូប សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ១រូប សមាជិក
- តំណាងនាយកដ្ឋានរដ្ឋបាលផែនការនិងហិរញ្ញវត្ថុនៃរដ្ឋបាលព្រៃឈើ១រូប សមាជិកអចិន្ត្រៃយ៍។

សមាសភាពជាក់ស្តែងរបស់គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៨ ..**

គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិមានតួនាទីនិងភារកិច្ចដូចតទៅ៖

- កំណត់នូវគោលនយោបាយនិងយុទ្ធសាស្ត្រគ្រប់គ្រងនិងចាត់ចែងប្រើប្រាស់មូលនិធិអភិវឌ្ឍព្រៃឈើជាតិ
- ធ្វើការសម្របសម្រួលជាមួយរាជរដ្ឋាភិបាល ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍ វិស័យឯកជន និងសប្បុរសជនក្នុងការកៀរគរមូលនិធិអភិវឌ្ឍព្រៃឈើជាតិ
- ពិនិត្យនិងសម្រេចលើគម្រោងចំណូលចំណាយរបស់មូលនិធិសម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យព្រៃឈើតាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ
- ធ្វើរបាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុនិងរបាយការណ៍វឌ្ឍនភាពរបស់មូលនិធិអភិវឌ្ឍព្រៃឈើជាតិរៀងរាល់ត្រីមាសជូនរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៩ ..**

គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិមានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅរដ្ឋបាលព្រៃឈើ និងដឹកនាំដោយប្រធានរដ្ឋបាលព្រៃឈើ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិវឌ្ឍព្រៃឈើជាតិ។



www.pheakdeylaw.com

**មាត្រា១០ .-**

មូលនិធិអភិវឌ្ឍព្រៃឈើជាតិមានគ្រាដោយឡែកសម្រាប់ដំណើរការការងារ។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com